# សំឡេងមួយផ្សេងទៀត
# Another Sound

អាណន់ ណងយ៉ាវ ជាមួយ ខ្វៃ ឡឹង

Arnont Nongyao with Khvay Loeung

១៧ មករា - ៣០ មីនា ២០១៨
សម្ពោធ ថ្ងៃទី១៧ ខែមករា ម៉ោង ៦ ល្ងាច
ការសម្ដែងផ្ទាល់ ចាប់ផ្ដើមម៉ោង ៧ យប់

17 January – 30 March 2018
opening: 17 January, 6pm, live performance 7pm

Sa Sa Art Projects, #47 Street 350 (off Street 95)
Wed-Sat 10am-6pm | 092 961 974 | www.sasaart.info




1 *Another 1*, 2018.
Digital C-Print. 20 x 30 cm.

2 *Another 2*, 2018.
Digital C-Print. 20 x 30 cm.

3 *Another 3*, 2018.
Digital C-Print. 20 x 30 cm.

4 *Another Sound*, 2018.
Superimposed two-channel video with sound, 21mn,
DIY amplifier, CCTV camera, speaker.
Dimension varaiable.

5 *Another 5*, 2018.
Digital C-Print. 20 x 30 cm.

6 *Another 6*, 2018.
Digital C-Print. 20 x 30 cm.

7 *Another 7*, 2018.
Digital C-Print. 30 x 45 cm.

8 *Another Sound (record of live performance)*, 2018.
20mn

**អាណន់ ណងយ៉ាវ** (កើតឆ្នាំ ១៩៧៩ ទីក្រុងបាងកក ប្រទេសថៃ) រស់នៅ និងធ្វើការនៅទីក្រុងឈៀងម៉ៃ ។ គាត់បានបញ្ចប់ការសិក្សាផ្នែកគំនូរ ពីសាកលវិទ្យាល័យឈៀងម៉ៃ ប៉ុន្តែបានចាប់អារម្មណ៍លើរូបភាពមានចលនា និងសំឡេង ។ ការងារសិល្បៈរបស់គាត់ គឺផ្ដោតលើការដកពិសោធន៍អំពីរំញ័រ ដែលចេញពីមនុស្ស សារពាង្គកាយ វត្ថុ និង ទម្រង់ផ្សេងៗនៃសង្គម។ ស្នាដៃរបស់គាត់ ជាធម្មតាបង្ហាញក្នុងទម្រង់សម្ដែង (performance) និងការដំឡើង (installation) ហើយជាញឹកញាប់នៅកន្លែងជាក់លាក់ ឬទីសាធារណៈ ។ អាណន់ បានបង្ហាញស្នាដៃសិល្បៈរបស់គាត់យ៉ាងទូលំទូលាយ នៅឯពិធីតាំងពិព័រណ៌ និងពិធីមហោស្រពជាច្រើនទាំងក្នុងប្រទេសថៃ និងអន្តរជាតិ រួមទាំងនៅឯមហោស្រពជំនួនអាស៊ី ២០១៧ នៅប្រទេសជប៉ុន, កម្មវិធី AVATAR´s Bangkok-Quebec Exchange Program នៅប្រទេសកាណាដា ឆ្នាំ ២០១៦ និង កម្មវិធី the 16th Media Art Biennale WRO ២០១៥ នៅប្រទេសប៉ូឡូញ ។ គាត់ធ្លាប់បានធ្វើនិវាសដ្ឋានសិល្បៈនានាជាច្រើនរួមមាន នៅឯ  BACC និង AVATAR នៅទីក្រុងបាងកកនិងគូបិច ដែលជាផ្នែកមួយនៃគម្រោងផ្លាស់ប្ដូរ Bangkok-Quebec Exchange Program ២០១៦ នៅ Koganecho Bazaar ទីក្រុង យ៉ូកូហាម៉ា ប្រទេសជប៉ុន ឆ្នាំ ២០១៥ និងនៅ គម្រោងសិល្បៈស-ស ទីក្រុងភ្នំពេញ ឆ្នាំ ២០១៥ ។ អាណន់ ជាសហនាយកនៃក្រុម Chiang Mai Collective (CMC) ដែលជាបណ្ដាញបើកចំហនៃសិល្បករសិល្បការិនីច្នៃប្រឌិត និងអ្នកបង្កើតសំឡេង នៅទីក្រុងឈៀងម៉ៃ ។

**ខ្វៃ ឡឹង** (កើតឆ្នាំ ១៩៤០ ខេត្តស្វាយរៀង ប្រទេសកម្ពុជា) ជាអ្នកឯកទេស និងអ្នកបង្កើតសំឡេង ។ គាត់ ក៏ជាអាចារ្យ សម្រាប់ពិធីបុណ្យសពផងដែរ ។ ដោយមានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើផ្នែកអេឡិចត្រូនិច លោកអ៊ំ ឡឹង បានរៀននិងសាកល្បងដកពិសោធន៍ដោយខ្លួនឯងជាមួយការងារបង្កើតសំឡេង ។ គាត់បានបង្កើតនិងកែច្នៃឧបករណ៍សំឡេងដោយខ្លួនឯង សម្រាប់ការងាររបស់គាត់នៅតាមពីធីបុណ្យសព ដែលគាត់ដើរតួនាទីជាអ្នកសម្របសម្រួលពីធី និងផ្ដល់សេវាកម្មឧបករណ៍ និងចាក់សំឡេងសម្រាប់ពិធីបុណ្យ ។ លោកអ៊ំតែងតែបន្តកែច្នៃឧបករណ៍សំឡេងរបស់គាត់ឥតឈប់ឈរ មានដូចជាអំភ្លី និងឧបករណ៍បំពងសំឡេងជាដើម ។

**Arnont Nongyao** (b. 1979, Bangkok) lives and works in Chiang Mai. He graduated in Painting from Chiang Mai University but became interested in sound and moving images. His practice centres on experimentation with vibrations that are derived from humans, organisms, things, and social forms. His works usually result in performance or installation, often in site-specific or public spaces. Arnont has presented works widely at various exhibition and festival platforms locally and internationally, including at The Asian Meeting Festival 2017, Japan; AVATAR's Bangkok-Quebec Exchange Program, Canada, 2016; and the 16th Media Art Biennale WRO 2015, Wroclaw, Poland. He has undertaken some art residencies including at BACC and AVATAR, Bangkok and Quebec respectively, as part of Bangkok-Quebec Exchange Program 2016; at Koganecho Bazaar, Yokohama, Japan, 2015; and at Sa Sa Art Projects, Phnom Penh, 2015. Arnont is Co-Director of Chiang Mai Collective (CMC), an open network of innovative sound artists and practitioners in Chiang Mai.

**Khvay Loeung** (b. 1940, Svay Rieng) is a sound specialist and inventor. He is also an Ajar for funeral ceremonies. With a strong interest in electronics, Loeung self-teaches and experiments with sound creation. He creates and modifies DIY sound equipment for his work at the funerals. Loeung and Arnont have previously worked together during Arnont's residency at Sa Sa Art Projects in Phnom Penh in 2015.

«សំឡេងមួយផ្សេងទៀត» គឺជាពិព័រណ៍ទោលលើកដំបូងនៅភ្នំពេញ របស់សិល្បករ អាណន់ ណងយ៉ាវ មកពីទីក្រុងឈៀងម៉ៃ ។ វាក៏ជាលើកទីមួយផងដែរដែល អាណន់ តាំងពិព័រណ៍ជាមួយដៃគូរសហការ លោកអ៊ំ ខ្វៃ ឡឹង ដែលជាអ្នកបង្កើតសំឡេងប្រចាំនៅភ្នំពេញ ។ គម្រោងនេះ កើតចេញមកពីការចង់ដឹងចង់យល់និងបន្តសន្ទនារបស់ អាណន់ ជាមួយលោកអ៊ំ ខ្វៃ ឡឹង ដែលគាត់ទាំងពីរនាក់បានជួបគ្នាជាលើកដំបូងកាលពីពេល អាណន់ មកធ្វើនិវាសដ្ឋានជាមួយគម្រោងសិល្បៈស-ស នៅឆ្នាំ ២០១៥ ។

ពិព័រណ៍នេះ បង្ហាញពីស្នាដៃរូបមានចលនា សំឡេង និងរូបថត ដោយពិនិត្យលើវិធីសាស្ត្រទំនាក់ទំនង និងទស្សនៈការស្លាប់ឬក៏ការរសាត់ទៅភពថ្មីនៃជីវិតតាមរយៈការសម្របសម្រួលនៃសំឡេង និងរូបភាព ។ នៅចំកណ្ដាលនៃសាលពិព័រណ៍ មានវីដេអូពីរបញ្ចាំងត្រួតលើគ្នា ។ ស្រទាប់ទីមួយនៃវីដេអូ បង្ហាញពីពិភពពីរដំណាលគ្នារបស់លោកអ៊ំ ខ្វៃ ឡឹង ក្នុងនាមជាអាចារ្យពិធីបុណ្យសពផង និងជាអ្នកបង្កើតសម្លេងនៅក្នុងបន្ទប់គេង/ស្ទូឌីយោរបស់គាត់ផង។ នៅឯពិធីបុណ្យសព លោកអ៊ំ ដើរតួនាទីជាអ្នកសម្របសម្រួលនៃកម្មវិធី រវាងព្រះសង្ឃ ពុទ្ធសាសនិក និង អ្នកស្លាប់ ។ គាត់ ដំឡើងនិងដំណើរការប្រព័ន្ធសំឡេងរបស់គាត់ សូត្រធម៌ និងចាក់ភ្លេងនិងចំរៀងសម្រាប់ពិធីបុណ្យ ។ នៅឯផ្ទះក្នុងបន្ទប់គេងរបស់គាត់វិញ ទស្សនិកជនមើលឃើញពីកន្លែងនិងរបៀបដែលគាត់បង្កើតប្រព័ន្ធសំឡេងរបស់គាត់៖ ឧបករណ៍អេឡិកត្រូនិកជាច្រើន រាយគរណែនណាន់តាន់តាប់តាមជញ្ជាំង និងលើកំរាលឥដ្ឋ ខណៈដែលគាត់និង អាណន់ ធ្វើតេស្តឧបករណ៍របស់ពួកគេ និងបង្កើតសំឡេងជាមួយគ្នា ។ ទន្ទឹមនឹងនេះ ស្រទាប់វីដេអូមួយទៀត គឺជាការរូបភាពដែលថតនិងផ្សាយផ្ទាល់ពីផ្ទៃខាងក្នុងនៃឧបករណ៍អំភ្លីបង្កើតដោយ លោកអ៊ំ ឡឹង ។ អំភ្លីនេះ ត្រូវបានដំឡើងនៅលើផ្នែកមួយនៃកំរាលឥដ្ឋរបស់សាលពិព័រណ៍ដែលបែក និងបង្ហាញអោយឃើញនូវផ្ទៃបេតុងនៅក្រោមសន្លឹកការ៉ូ ដែលវាបានប្រែក្លាយបញ្ចូលទៅជាផ្នែកមួយនៃស្នាដៃនេះ ។

អំភ្លីដែលបើកគម្របនេះ បង្ហាញពីផ្នែកខាងក្នុងនៃម៉ាស៊ីនឬក៏រាងកាយ ដែលកំពុងត្រូវបានពិនិត្យអង្កេតតាមរយៈម៉ាស៊ីនថត ។ សំឡេងរបស់វា ដែលកើតចេញពីការរំខាននៃចរន្តផ្សេងៗ ត្រូវបានថតនិងបន្លឺឡើងតាមរយៈឧបករណ៍បំពងសំឡេងចាស់មួយ ដែលត្រូវបានយកមកកែច្នៃប្រើជាថ្មី ។ ឧបករណ៍បំពងសំលេងនេះ និងអវតារូបភាពនិងសំឡេងរបស់វា ព្រមទាំងវីដេអូ និងរូបថតផ្លាកសញ្ញានានានៅតាមជញ្ជាំងនៃសាល វាទាំងអស់ហាក់ដើរតួសម្ដែងជាផ្នែកខាងក្នុងនៃបន្ទប់អំភ្លីធំមួយដូច្នោះដែរ ឬបើតាមសំដីរបស់ អាណន់ វាហាក់ដូចជាតួអក្សរ ។ តែក្នុងករណីនេះ តួអក្សរទាំងនេះមិនអាចយល់បានទេ តែអាចទទួលតាមអារម្មណ៍ និងញាណបាន ។ ដោយសិល្បករទាំងពីររូបមានឧបសគ្គមិនអាចនិយាយភាសាដូចគ្នាបាន ស្នាដៃដែលលើកមកបង្ហាញនេះ មិនមែនគ្រាន់តែជាលទ្ធផលនៃការសហការគ្នារបស់ពួកគេនោះប៉ុណ្ណោះទេ ប៉ុន្តែតាមពិតទៅវាក៏ជាវិធីសាស្ត្រនៃការសហការគ្នារបស់ពួកគេតែម្ដង ។ ពួកគេព្យាយាមយល់ពីគ្នាទៅវិញទៅមក តាមរយៈការដកពិសោធន៍សំឡេង ឬក៏និយាយម្យាងទៀតថាតាមរយៈភាសា*សម្លេងមួយផ្សេងទៀត* ។

ពិព័រណ៍នេះ បង្ហាញជូននូវភាពស្មោះត្រង់នៃលក្ខខណ្ឌសម្ភារៈ ក្នុងនាមជាទម្រង់មួយនៃភ្នាក់ងារសកម្ម ។ ការពិសោធន៍នៃសម្ភារៈ ក៏ដូចជាការប្រើសំឡេងដែលបានមកពីរូបធាតុនានា មានលក្ខណៈស្របគ្នានៅក្នុងការងាររបស់ អាណន់ និង លោកអ៊ំ ឡឹង ។ ខណៈពេលដែល អាណន់ ទាញយកវត្ថុដែលប្រើរួច វត្ថុដែលមានកំហុស និងវត្ថុដែលខូចខាតមកជាប្រភពសម្រាប់ការបំផុសគំនិតនៃការច្នៃប្រឌិតថ្មី លោកអ៊ំ ឡឹង ប្រើប្រព័ន្ធផ្សព្វផ្សាយដែលជាសម្ភារៈសម្រាប់សម្របសម្រួលដល់ការស្លាប់ និងចាប់កំណើតឡើងវិញក្នុងពិធីបុណ្យសព ទៅជាប្រភពសម្រាប់បន្តច្នៃបង្កើតសារជាថ្មី ។

*Another Sound* is Phnom Penh's first solo exhibition by Chiang Mai-based artist Arnont Nongyao. It is also the first time that Arnont exhibits with guest collaborator Khvay Loeung, a sound inventor from Phnom Penh. The project stems from Arnont's curiosity to connect and continue a conversation with Loeung who he first met in 2015 during his residency with Sa Sa Art Projects.

The exhibition presents moving images, sound and photographs exploring an experimental approach to communications and a concept of life passing-on through sonic and visual mediations. At the centre of the exhibition space is a video of two moving images projected on top of each other. One layer of the videos interweaves two parallel worlds of Khvay Leung as an Ajar at funeral services and as a sound inventor in this bedroom/studio. At the funerals, Loeung works at a mediator of the ceremony facilitating between monks, laypeople and the dead. He sets up and controls his sound system, chants, and ensures the event is equipped with music and songs needed. At home in his bedroom, the audience sees where and how his sound system is made: electronic parts crowd the walls and the floor as Loeung and Arnont test their equipment and make sound together. Meanwhile, another layer of the videos is a live projection of the interior of Loeung's homemade amplifier. It is installed on a part of the floor which is cracked, exposing the concrete underneath the tiles integrated into the work.

The exposed amplifier proposes an opening into the interior of the body which is being examined through the interrogation of the camera. Its noise, which is produced through the interruption of various signals, is projected out through a repurposed speaker. The amplifier and its extension of sound and moving image together with the videos and photograph signposts on the walls, all perform like an interior of an amplifier-room, or, according to Arnont, act like a kind of alphabet. The alphabet, however, in this case cannot be deciphered, but can only be felt and sensed. Because of the communication barrier between the two artists—who do not share a common language—the presented work is not only a result of their collaboration but in fact also the very method of their collaboration. They attempt to achieve a mutual understanding through a sonic experimentation: through *another sound* language.

The exhibition brings to bear the honesty of material conditions as a form of active agent. The experimentation of materiality, as well as the use of sound derived from physical matters, is mirrored in both practices of Anont and Loeung. While, for Anont, the used, the error and the broken are sources for inspiration of new innovation, for Loeung, the very media used for mediating death-rebirth of funerals are the source for continued reinvention.





